ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ១ រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២០*

## សេចក្ដីប្រកាសព័ត៌មាន

## កិច្ចប្រជុំចង្អៀតនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) ស្ដីពីសេចក្ដីព្រាងយុទ្ធសាស្ត្រស្ដីពីការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ

នាព្រឹកថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២០, នៅទីស្ដីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើ ***"សេចក្ដីព្រាងយុទ្ធសាស្ត្រស្ដីពីការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ"*** ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្ដមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា, ឯកឧត្ដមបណ្ឌិតសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ព្រមទាំងថ្នាក់ដឹកនាំជាន់ខ្ពស់ពីក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ។

ជាការឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងដើម្បីធានាបាននូវសុវត្ថិភាពរបស់សិស្សានុសិស្ស, បុគ្គលិកសិក្សា, បុគ្គលិកបម្រើការផ្សេងទៀត និងសហគមន៍ទាំងមូល ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំឱ្យគ្រប់គ្រឹះស្ថានសិក្សានៅទូទាំងប្រទេសកម្ពុជាផ្អាកដំណើរការចាប់តាំងពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ កន្លងមក ។ ការវាយតម្លៃរបស់ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញឱ្យឃើញថា នៅក្នុងឆ្នាំ ២០២០ និង ២០២១ នេះ គ្រឹះស្ថានសិក្សាគ្រប់ប្រភេទនឹងមិនអាចមានដំណើរការបានដូចមុនពេលមានវិបត្តិនៃជំងឺកូវីដ-១៩ ឡើយ ។ គ្រឹះស្ថានសិក្សា ត្រូវសម្របសម្រួលទៅតាម **"ជីវិតរស់នៅធម្មតាតាមគន្លងបែបថ្មី"** (New Normal Life) តាមរយៈការអនុវត្ត **"វិធានការសុវត្ថិភាពសិក្សា"** ដើម្បីការពារសុវត្ថិភាពអ្នកសិក្សា, បុគ្គលិកសិក្សា, បុគ្គលិកបម្រើការផ្សេងទៀត និងផ្ដល់ទំនុកចិត្តដល់មាតាបិតា ។ ក្នុងបរិការណ៍នេះ, ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំ ***"យុទ្ធសាស្ត្រស្ដីពីការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ"*** ដោយឈរលើអភិក្រម ២ គឺ÷ ១. ការបើកដំណើរការឡើងវិញតាមដំណាក់កាល

នូវគ្រឹះស្ថានសិក្សាដែលអាចអនុវត្តបានត្រឹមត្រូវតាម **“ស្តង់ដាសុវត្ថិភាពសុខភាព”** និង ២. ការបន្តអនុវត្តវិធីសាស្ត្រនៃការសិក្សាតាមបែបចម្រុះ គឺការសិក្សាក្នុងថ្នាក់រៀន, ការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក (distance and e-learning) និងតាមបែបប្រពៃណី (សន្លឹកកិច្ចការជំនួយ) រួមទាំងការធ្វើស្វ័យសិក្សា (សម្រាប់សិស្សនៅទីជនបទ) ។ ដោយឈរ លើអភិក្រមទាំងពីរនេះ ***“យុទ្ធសាស្ត្រស្តីពីការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ”*** ត្រូវបានរៀបចំឡើងដោយឈរលើគោលការណ៍ ចំនួន ០៥ ចំណុច រួមមាន÷

១. ក្រសួងរៀបចំការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញជា ៣ ដំណាក់កាល បន្តបន្ទាប់គ្នា ។

២. គ្រឹះស្ថានសិក្សាមិនទាន់អាចដំណើរការឡើងវិញពេញលេញនៅឡើយ និងត្រូវអនុវត្តនូវវិធីសាស្ត្រចម្រុះគឺការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក និងតាមប្រព័ន្ធប្រពៃណី (សម្រាប់ទីជនបទ) រួមជាមួយនឹងការសិក្សានៅក្នុងថ្នាក់រៀន ។

៣. ការអនុញ្ញាតឱ្យបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញតាមដំណាក់កាលនីមួយៗ បន្ទាប់ពីគ្រឹះស្ថានសិក្សាទាំងនោះបានត្រៀមខ្លួនរួចរាល់ និងអនុវត្តបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវសុវត្ថិភាពដែលកំណត់ដោយក្រសួងសុខាភិបាល និងលក្ខខណ្ឌតម្រូវបច្ចេកទេសនៃការសិក្សា និងការបង្រៀន ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ។

៤. ការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ គឺឈរលើគោលការណ៍ស្ម័គ្រចិត្ត ដោយមានការទទួលខុសត្រូវខ្ពស់ និងការប្តេជ្ញាចិត្តក្នុងការអនុវត្តវិធានការសុវត្ថិភាពសុខភាពរបស់ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក ព្រមទាំងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។

៥. ការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ ក៏ឈរលើគោលការណ៍នៃទីតាំងភូមិសាស្ត្រនៃកម្រិតហានិភ័យរបស់ការរាលដាលនៃជំងឺកូវីដ-១៩ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ ក៏បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់ក្រុមការងារនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានផ្តល់ជាធាតុចូល និងរៀបចំឯកសារដ៏មានសារៈសំខាន់នេះ និងស្នើឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធបន្តផ្តល់កិច្ចសហការ និងកែសម្រួលឯកសារនេះតាមស្មារតីនៃអង្គប្រជុំ ដើម្បីឱ្យឯកសារនេះមានភាពពេញលេញ គ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបានក្នុងពេលឆាប់ៗខាងមុខនេះ ។